ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
* * * * * *

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
* * * * * *

# កម្ពុជា និងបណ្តាទីភ្នាក់ងារអ.ស.ប នឹងបន្តកិច្ចសហប្រតិបត្តិការភាពជាដៃគូ ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ប្រកបដោយគុណភាព សមធម៌ បរិយាប័ន្ន និងចីរភាព

* * * * * *

បន្ទាប់ពីទទួលលិខិតសារតាំង (Letter of Credentials) របស់លោកស្រី Pauline Tamesis ក្នុងឋានៈជាតំណាងថ្មីនៃកម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាតិប្រចាំកម្ពុជា (UNDP Resident Representative) និងជាអ្នកសម្របសម្រួលប្រព័ន្ធអង្គការសហប្រជាតិនៅកម្ពុជា (UN Resident Coordinator) នៅក្នុងជំនួបព្រឹកថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៨ ឯកឧត្តមទេសរដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានសម្តែងនូវការអបអរសាទរយ៉ាងកក់ក្តៅចំពោះការចូលកាន់ការងាររបស់លោកស្រីក្នុងតួនាទីដ៏សំខាន់នេះ និងការចាប់អារម្មណ៍របស់ឯកឧត្តមចំពោះបទពិសោធន៍របស់លោកស្រី ក្នុងការងារកម្មវិធីអភិវឌ្ឍន៍អ.ស.ប នៅតាមប្រទេសក្នុងតំបន់អាស៊ី។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ចំពោះការរួមវិភាគទានដ៏សកម្មរបស់កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាតិ និងរបស់បណ្តាទីភ្នាក់ងារអ.ស.បផ្សេងទៀត តាមរយៈក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍របស់អ.ស.ប ចំពោះកម្ពុជា (UN Development Assistance Framework-UNDAF) ហើយនិងកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយរាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ការអភិវឌ្ឍនិងការគាំពារសង្គម ការអភិវឌ្ឍធនធានមនុស្ស អភិបាលកិច្ចល្អ សិទ្ធិមនុស្ស ក៏ដូចជាក្នុងការជួយដល់កម្ពុជាសម្រេចបាននូវបណ្តាគោលដៅអភិវឌ្ឍន៍សហសវត្ស ព្រមទាំងក្នុងបេសកកម្មមនុស្សធម៌ ដូចជាការបោសសម្អាតមីននៅកម្ពុជា និងការចូលរួមរបស់កម្ពុជាក្នុងបេសកកម្មរក្សាសន្តិភាពក្រោមធ័ត្រអ.ស.ប។

**ឯកឧត្តមទេសរដ្ឋមន្ត្រី** បានរំលឹកពីលទ្ធផលផ្លែផ្ការនៃជំនួបប្រចាំឆ្នាំកាលពីខែកុម្ភៈកន្លងមក រវាង **សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី** និងសមាជិករាជរដ្ឋាភិបាល ជាមួយបណ្តាទីភ្នាក់ងារអ.ស.ប ដើម្បីពិភាក្សាផ្លាស់ប្តូរយោបល់គ្នាលើការពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការភាពជាដៃគូ រវាងរាជរដ្ឋាភិបាល ជាមួយបណ្តាទីភ្នាក់ងារអ.ស.ប ហើយ**ឯកឧត្តម**បានចាត់ទុកជំនួបនោះជាមេរៀនពិសោធន៍ដ៏ល្អមួយទៅអនាគតទៀត សម្រាប់ការស្វែងរកវិធី និងរូបមន្ត ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការនេះ។

លោកស្រី Pauline Tamesis បានចាត់ទុកថាជាកិត្តិយសដ៏ថ្លៃថ្លា និងជាមោទនភាពរបស់លោកស្រីដែលត្រូវបានតែងតាំងឲ្យមកបំពេញមុខងារខាងលើនៅកម្ពុជា និងបានសំដែងការអបអរសាទរចំពោះការរីកចំរើនដ៏ខ្លាំងក្លា សន្តិភាព និងស្ថេរភាព ដែលកម្ពុជាសំរេចបាន។ **លោកស្រី**ក៏បានអបអរសាទរចំពោះការរីកចំរើនគួរកត់សំគាល់ក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ការវិវឌ្ឍរបស់កម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកំរិតទាប ការខិតខំរបស់កម្ពុជាក្នុងការបោសសំអាតមីន ការសំរេចរបស់រាជរដ្ឋាភិបាលក្នុងការបញ្ចូលការបោសសំអាតមីនជាគោលដៅអភិវឌ្ឍទី១៨ ហើយនិងការចូលរួមយ៉ាងសកម្មរបស់កម្ពុជានៅក្នុងបេសកកម្មរក្សាសន្តិភាពអ.ស.ប។

ជាការឆ្លើយតប **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានគូសបញ្ជាក់អំពីកាខិតខំរបស់រាជរដ្ឋាភិបាល ក្នុងការបោសសម្អាតមីន ការថយចុះយ៉ាងខ្លាំងនៃចំនួនអ្នករងគ្រោះដោយសារគ្រាប់មីនពីចំនួន៤.៣២០នាក់ ក្នុង

ឆ្នាំ១៩៩៦ មកនៅត្រឹមតែ៥៦នាក់ ក្នុងឆ្នាំ២០១៧ តែ**ឯកឧត្តម**បានគូសបញ្ជាក់ថារដ្ឋាភិបាលនៅតែចាត់ទុកបញ្ហាមីន ជាឧបសគ្គនៃការអភិវឌ្ឍជនបទ ដែលត្រូវតែបន្តផ្តោតការយកចិត្តទុកដាក់ខ្ពស់ ហើយនេះជាមូលហេតុដែលកម្ពុជាចាត់ទុកការបោសសំអាតមីនជាគោលដៅទី១៨ ក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់ខ្លួន។ **ឯកឧត្តម**ក៏បានលើកឡើងផងដែរពីមោទនភាពរបស់កម្ពុជាក្នុងការបញ្ជូនកងកំលាំងមួកខៀវ ចំនួន៥.១៧២នាក់ ទៅចូលរួមក្នុងបេសកកម្មរក្សាសន្តិភាពអ.ស.ប នៅតាមប្រទេសចំនួន៨ ចាប់តាំងពីឆ្នាំ២០០៦ រហូតមកដល់បច្ចុប្បន្ននេះ។

នៅក្នុងជំនួបនេះដែរ **ឯកឧត្តមទេសរដ្ឋមន្ត្រី** ក៏បានឆ្លៀតពន្យល់បកស្រាយជូនលោកស្រី Pauline Tamesis នៅលើការជូនពររបស់លោកស្រី Claire Van der Vaeren នៅពេលលោកស្រីចប់អាណត្តិ។ ទី១ ការរីកចម្រើននៃលិទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ដោយ**ឯកឧត្តម**បានគូសបញ្ជាក់ថាលទ្ធិប្រជាធិបតេយ្យនឹងបន្តរីកចំរើន ស្របទៅតាមបរិបទរបស់កម្ពុជា នោះគឺការផ្តល់អាទិភាពចំបងដល់សន្តិភាព និងស្ថេរភាពទន្ទឹមនឹងនោះខិតខំរក្សាការពារឲ្យបាននូវឯករាជ្យ និងអធិបតេយ្យ ប្រឆាំងការជ្រៀតជ្រែករបស់បរទេសចូលកិច្ចការផ្ទៃក្នុងកម្ពុជា។ ទី២ ការពង្រឹងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស ដោយ**ឯកឧត្តម**បានគូសបញ្ជាក់ថា ការចុះហត្ថលេខារបស់រាជរដ្ឋាភិបាល បន្តសុពលភាពអនុស្សរណៈនៃការយោគយល់គ្នាសម្រាប់ការអនុវត្តកម្មវិធីនៃកិច្ចសហប្រតិបត្តិការបច្ចេកទេសលើវិស័យសិទ្ធិមនុស្សនៅកម្ពុជា សម្រាប់រយៈពេល២ឆ្នាំ (ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ ដល់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៨) ដែលបានបើកផ្លូវឲ្យការបន្តអាណត្តិរបស់អ្នករាយការណ៍ពិសេសរបស់អ.ស.ប ស្តីពីសិទ្ធិមនុស្សនៅកម្ពុជា ក៏ដូចជាអនុស្សរណៈនៃការយោគយល់គ្នាដើម្បីបន្តវត្តមានរបស់ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សអ.ស.ប នៅកម្ពុជា បានបង្ហាញច្បាស់ពីឆន្ទៈរបស់រាជរដ្ឋាភិបាលក្នុងការលើកស្ទួយ និងការការពារសិទ្ធិមនុស្ស។ **ឯកឧត្តម**បានគូសបញ្ជាក់ថាក្នុងពេលដែលជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាត្រូវបានលើកកម្ពស់យ៉ាងខ្លាំង ដែលតាមរយៈនោះជានាបាននូវសិទ្ធិសេរីភាពជាមូលដ្ឋានជាច្រើន រាជរដ្ឋាភិបាលក៏ទទួលស្គាល់ផងដែរពីតម្រូវការនៃការលើកកម្ពស់សិទ្ធិសេរីភាពផ្សេងៗទៀត។ ទី៣ ការបន្តអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ជាមួយការផ្តោតការយកចិត្តទុកដាក់ទៅលើគុណភាព សមធម៌ បរិយាប័ន្ន និងចីរភាព ដោយ**ឯកឧត្តម**បានគូសបញ្ជាក់ថានៅក្នុងកិច្ចប្រជុំរវាង**សម្តេចតេជោនាយករដ្ឋមន្ត្រី** ជាមួយបណ្តាភ្នាក់ងារអេ.ស.ប ក្រសួងស្ថាប័នពាក់ព័ន្ធកម្ពុជាបានបង្ហាញយ៉ាងច្បាស់អំពីទស្សនវិស័យ យុទ្ធសាស្ត្រ ផែនការ កម្មវិធី និងគំរោងនានារបស់ខ្លួន ក្នុងការបន្តការអភិវឌ្ឍតាមលក្ខណៈខាងលើ ព្រមទាំងការលំបាក និងការប្រឈមនានា ដែលត្រូវបន្តដោះស្រាយដោយមានការជួយឧបត្ថម្ភរបស់បណ្តាទីភ្នាក់ងារអេ.ស.ប។

ឆ្លើយតបនឹងការលើកឡើងរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី លោកស្រី Tamesis បានគូសបញ្ជាក់ថាកម្មវិធីអភិវឌ្ឍន៍អ.ស.ប និងបណ្តាទីភ្នាក់ងារអេ.ស.ប នឹងបន្តកិច្ចសហប្រតិបត្តិការ និងការពង្រឹងភាពជាដៃគូជាមួយកម្ពុជា។ **លោកស្រី** ក៏បានជំរាបជូន **ឯកឧត្តមទេសរដ្ឋមន្ត្រី** អំពីការត្រៀមរៀបចំរបស់កម្មវិធីអភិវឌ្ឍន៍អ.ស.ប និងបណ្តាទីភ្នាក់ងារអេ.ស.ប នូវក្របខ័ណ្ឌជំនួយអភិវឌ្ឍន៍អ.ស.ប ចំពោះកម្ពុជាថ្មីមួយ សម្រាប់ឆ្នាំ២០១៩-២០២៣ ហើយ**លោកស្រី**នឹងបន្តសំរបសំរួលជាមួយបណ្តាក្រសួងស្ថាប័នកម្ពុជាក្នុងការត្រៀមរៀបចំនេះ។

ជំនួបនេះ បានបញ្ចប់ក្នុងបរិយាកាសរីករាយ និងស្និទ្ធស្នាល។

ថ្ងៃ ពុធ ១២កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ភ្នំពេញ, ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ២០១៨